**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៣១/០៦/២០១១ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១១

**ជម្រាបមក**

**លោក ហ៊ីង យឿន**

ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៦៩ AE3 ផ្លូវលេខ ១៧៨ ភូមិ៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ជាតំណាងលោក **សេក គឹម** និងលោក **អ៊ួន សំណាង** ដែលជាតំណាងគណបក្ស សម រង្ស៊ី

**កម្មវត្ថុ** : រឿងទាក់ទងនឹងពាក្យបណ្តឹងជំទាស់នឹងគោលការណ៍ គ.ជ.ប ដែលនៅតែរក្សាទុកក្នុងបញ្ជីបោះឆ្នោត នូវឈ្មោះជនជាតិវៀតណាមមួយចំនួនដែលពុំមានសញ្ជាតិខ្មែរ ដោយផ្អែកលើឯកសារបញ្ជាក់អត្តសញ្ញាណ និងប័ណ្ណបោះឆ្នោតកន្លងមកដែលមិនត្រឹមត្រូវតាមល័ក្ខខ័ណ្ឌនៃច្បាប់សញ្ជាតិ

**យោង** : ពាក្យបណ្តឹងរបស់លោក លេខ ១៣៦/១១ គសរ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបលោកថា ក្នុងកិច្ចប្រជុំនាថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១១ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើពាក្យបណ្តឹងរបស់លោក រួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា តាមមាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងមាត្រា ៦៥ ថ្មី (ពីរ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បណ្តឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទេ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**